ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ៥

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាពការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែឧសភា ឆ្នាំ២០១៧



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| ១- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស | ១-២ |
| ២- សេចក្តីព្រាងអនុក្រឹត្យស្តីពី លក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់គារកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន | ៣-៤ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) | |
| - វគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ៥-៦ |
| III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមេសា ឆ្នាំ២០១៧ | ៧-១៤ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៧ | ១៥-១៧ |

## ១- សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌល តំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស

កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡាំ ខា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍ សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី តំណាងក្រសួងអប់រំ យុវជន និងកីឡា។



អនុវត្តតាមរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស សំដៅពង្រឹងគុណភាពនៃការបណ្តុះបណ្តាលសិស្សនិស្សិតដែលនឹងក្លាយជាធនធានមនុស្សមានសមត្ថភាពខ្ពស់តាមតម្រូវការទីផ្សារក្នុងប្រទេស និងក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោក ហើយក៏ស្របទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំដែលបានដាក់ចេញក្នុងនីតិកាលទី៥ នៃរដ្ឋសភា។

ការបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេសរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិមន្ត្រីរាជការ សិស្ស និស្សិតរួមចំណែកពង្រឹងគុណភាពអប់រំដើម្បីសម្រេចចក្ខុវិស័យឆ្នាំ២០៣០ ដែលរាជរដ្ឋាភិបាល ចង់ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ ខាងមុខ។ គោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជាឆ្នាំ២០១៨-២០២៥ មានគោលដៅប្រែក្លាយវិស័យឧស្សាហកម្មកម្ពុជា ដែលពឹងផ្អែកលើ



កម្លាំងពលកម្ម ទៅជាឧស្សាហកម្មដែលប្រើប្រាស់ជំនាញខ្ពស់នៅឆ្នាំ២០២៥ ដើម្បីសម្រេចគោលដៅនេះ ការអប់រំបច្ចេកទេស គឺជាកត្តាសំខាន់មួយមិនអាចខ្វះបានដែលក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការឲ្យរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់លើកកម្ពស់ការសិក្សាស្រាវជ្រាវលើការងារបច្ចេកទេសនេះឲ្យកាន់តែប្រសើរឡើង[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង នាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស។

## ២- សេចក្តីព្រាងអនុក្រឹត្យស្តីពី

### លក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិក ផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លីវ សុណ្ណា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពី លក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈបានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិក សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់ មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន លើកលែងតែអតីតយោធិនដែលមានឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ និងឧត្តមនាវី ដែលបានទួលរបបព្យាបាលពិសេសតាមស្មារតី នៃអនុក្រឹត្យលេខ ១៩៩ អនក្រ. បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។

មន្ត្រីសាធារណៈដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារនៅពេលទទួលរងហានិភ័យការងារ។

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ រួមមាន៖

- ការព្យាបាល និងថែទាំមុខរបួស ឬជំងឺដែលបណ្តាលមកពីហានិភ័យការងារ តាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ ទោះដោយសម្រាក ឬ មិនសម្រាកនៅក្នុងមន្ទីរពេទ្យក្តី រហូតដល់ជាសះស្បើយ

- ការផ្ដល់សេវាសង្គ្រោះបន្ទាន់

- ការផ្គត់ផ្គង់ឱសថសម្រាប់ព្យាបាល និងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល

- ការផ្ដល់សេវាស្ដារនីតិសម្បទា មានជាអាទិ៍ ការផ្គត់ផ្គង់ ការថែទាំ ឬ ជួសជុលឧបករណ៍អវៈយវៈ ឬសរីរាង្គសិប្បនិម្មិត ឬការកែទម្រង់រាងកាយដែលតម្រូវដោយគ្រូពេទ្យផ្លូវការ ការសម្របសម្រួលមុខងារ ឬការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈឡើងវិញ

- ការផ្ដល់សេវាដឹកសព ឬបញ្ជូនជនរងគ្រោះពេលសង្គ្រោះបន្ទាន់[១]៕

---

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្ដល់តាវកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

# វគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃ លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## (Regulatory Impact Assessment Methodology)

### នៅទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧

នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment Methodology) ជូនដល់មន្ត្រីក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តនៅ ECOSOCC និងមន្ត្រីក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តមកពីក្រសួង ស្ថាប័នចំនួន ១២ រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងរ៉ែនិងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការពារជាតិ មានសិក្ខាកាមសរុបប្រមាណ ៦០នាក់ ដែលនឹងសិក្សាអស់រយៈពេល៤ថ្ងៃចាប់ពីថ្ងៃទី០២ ដល់០៥ ខែឧសភា ឆ្នាំ២០១៧។

កម្មវិធីបើកវគ្គបណ្តុះបណ្តាលនេះស្ថិតក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុល សន** អនុប្រធាន ECOSOCC និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ហើយវាគ្មិនក្នុងវគ្គបណ្តុះបណ្តាលនេះ រួមមាន ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរង ECOSOCC និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ឯកឧត្តម **អេង រត្នមុន្នី** អគ្គលេខាធិការរង ECOSOCC និងជា



ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត



ប្រធានផ្នែកបណ្តុះបណ្តាលនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ក្នុងនោះក៏មានវាគ្មិនកិត្តិយសគឺ **លោក អ៊ុំ សាវី** អនុប្រធានក្រុមការងារវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និង លោក **នាង ម៉ៅ** អគ្គនាយករង នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត បានអនុវត្តសាកល្បងតាំងពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៧ ដែលECOSOCCជាអង្គភាពប្រតិបត្តិកម្មវិធី និងចូលរួមអនុវត្តកម្មវិធីដោយក្រសួងចំនួន១៣ ក្រោមហិរញ្ញប្បទានឥតសំណង និងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB។ ដោយការអនុវត្ត ទទួលបានលទ្ធផលល្អ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត៕



# III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមេសាឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំខែមេសា ឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ឈុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមេសាឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៤% ធៀបនឹងខែមុន និងកើនឡើង៣,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ការដឹកជញ្ជូន: | +៥,៩% | ប្រេងសាំង: | +១៥,៥% |
| ភោជនីយដ្ឋាន: | +៤,១% | ប្រេងម៉ាស៊ូត: | +១២,៦% |
| ម្ហូបអាហារ: | +៣,៨% | ត្រីស្រស់: | +៨,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៣,១% | បន្លែ: | +៥,៤% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,៧% | សាច់ជ្រូក: | +៣,៨% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +២,៦% | សាច់មាន់: | +៣,៥% |
| ការកំសាន្ត និងវប្បធម៌: | +១,៦% | សាច់គោ: | +៣,២% |
| សុខាភិបាល: | +១,២% | | |
| ទំនិញ និងសេវាកម្មផ្សេងៗ: | +០,៤% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា $^{P}$ | មិថុនា $^{P}$ | កក្កដា $^{P}$ | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ៣,២% | ៣,៧% | ៤,១% | | | | | | |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | ០,៤% | ០,៧% | ០,៧% | | | | | | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែ ឧសភា មិថុនា និងកក្កដា ឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១១.. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | មេសា ២០១៧ | មីនា ២០១៧ | មេសា ២០១៦ | *ប្រភេទ* | មេសា ២០១៧ | មីនា ២០១៧ | មេសា ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៣៤៛/១$ | ៤០០៥៛/១$ | ៤០៦០៛/១$ | **បាត/ដុល្លារ** | ៣៤,៥៩បាត/១$ | ៣៤,៤៩បាត/១$ | ៣៤,៩៩បាត/១$ |
| **៛/បាត** | ១១៧៛/១បាត | ១១៦៛/១បាត | ១១៦៛/១បាត | **ដុង/ដុល្លារ** | ២២៧៣០ដុង១$ | ២២៧៦៥ដុង១$ | ២២២៧៨ដុង/១$ |
| **៛/ដុង** | ០,១៧៧៛/១ដុង | ០,១៧៦៛/១ដុង | ០,១៨២៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមេសាឆ្នាំ ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥–២០១៧ (ប៊ីលានរៀល)




**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៦៥៣,៣ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤១៣,៣លានដុល្លារ (*មធ្យមប្រចាំខែ១១២% នៃផែនការ*) ក្នុងនោះ: ចំណូលចរន្តចំនួន១៤៩៨,៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៧៤,៦លានដុល្លារ (*មធ្យមប្រចាំខែ ១១១% នៃផែនការ*) និងចំណូលមូលធនមានចំនួន ១៥៤,៧ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៤៦៦% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ៧,៥% ប៉ុន្តែកើនឡើង២៥,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៣៧៣,៨ប៊ីលានរៀល ថយចុះ១៣,៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១១,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១២៤,៧ប៊ីលានរៀល ថយចុះ៣៦,៦%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៥៥,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -២,៣% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៨,៧%) | ➢កាស៊ីណូ : +២% | (+១៥,៥%) |
| ➢ ចំណូលពន្ធដារ: -១៣,៣% (អគ្គនាយកដ្ឋានពន្ធដារ) | (+១៧,៤%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៦៥,៨% | (+១០៤៦%) |
| | | ➢ នេសាទ: -៤៩,២% | (+៨៤,៧%) |
| | | ➢សម្បទានរ៉ែ: +១២,៦% | (+៣២៥,១%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +១,៦% | (-២០%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -១៥,១% | (+៥៤១៩%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): -៣៧,៣% | (+៨៧,៨%) |
| | | ➢ការត្រួតពិនិត្យគុណភាពផលិតផល: -២២,២% | (-១៧,៩%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៧៤៧,៣ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១៨៦,៨លានដុល្លារ( *មធ្យមប្រចាំខែ ៦២% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៦៣៥,៦ប៊ីលានរៀល ( *មធ្យមប្រចាំខែ ៦៦% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១១១,៧ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ៣៤,៨% ធៀបនឹងខែមុននិងថយចុះ៣,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៣២,៤% ធៀបនឹងខែមុនប៉ុន្តែកើនឡើង០,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៩០៥,៩ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២២៦,៥លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥–២០១៧
(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមេសា ឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ៦១៧២៥ប៊ីលានរៀល កើនឡើង១,៩% ធៀបនឹងខែមុន និងកើនឡើង ១៦,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្ដាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ១,៧% ប្រាក់បញ្ញើរមានកាលកំណត់និងសន្សំ១,៣% និងប្រាក់បញ្ញើជារូបិយបណ្ណ ២,១%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមេសា ឆ្នាំ២០១៧



➤ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៤% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៦% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៧

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៧% | ១៦,៦% | ១៥,៥% | ១៥,៣% | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | ១១,៣% | ១១,៣% | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមេសា២០១៧:ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➤**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៧៣៤៦លានដុល្លារ កើនឡើង២,៥%ធៀបនឹងខែមុន និងកើនឡើង៣៣,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ***: ក្នុងខែនេះមានចំនួន ២១៣០៦ប៊ីលានរៀលកើនឡើង១% ធៀបនឹងខែមុន និងកើនឡើង២៩,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មេសា២០១៧* | *មីនា២០១៧* | *មេសា២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ( ប៊ីលានរៀល ) | ៥៩៦៦៤ | ៥៨៨៧៨ | ៥៤០៧៣ |
| ក្នុងនោះ ជារៀល | | ១០១៤ | ៧៧២ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ( ប៊ីលានរៀល ) | | ១៣៦២៥ | ១១២៥១ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,០២% | ៦,៧១% | ៦,៥៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៤,៨៤% | ១៦,០៥% | ១៦,៧១% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤០% | ៤,៤៥% | ៤,៤៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦៤% | ១១,៦៧% | ១១,៥៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | | ២៣,៤% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | | ២៨,៨% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | | ២២,៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែមេសាឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➤**កសិកម្ម**:

✓នេសាទសម្រេចបាន៤៧,៦ពាន់តោន កើនឡើង៤%ធៀបនឹងខែមុន និងកើនឡើង២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៦៤៥,៨១GWHមានការកើនឡើង៨%ធៀបនឹងខែមុន និងកើនឡើង១០%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន២៤១,៩៣GWH មានការកើនឡើង១៥២%ធៀបនឹងខែមុន និងកើនឡើង៣៩២%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣០៧,០៧GWHមានការថយចុះ៨% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន(មិនទាន់ទទួលបានតួលេខ)។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –មេសា២០១៧ | ចំនួន–មីនា២០១៧ | ចំនួន–មេសា២០១៦ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៦ | ៨ | ០ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦០៧ | ១៥៩៣ | ១៥០១ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២១ | ២០ | ៦ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៨ | ១៨ | ១០ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៥៣២ពាន់ម៉ែ$^{2}$កើនឡើង២៨០%ធៀបនឹងខែមុន ប៉ុន្តែថយចុះ ២៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង២៧៤០,៥លានដុល្លារកើនឡើង៣៩៥%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៣៣%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^{2}$ –មេសា២០១៧ | ពាន់ម$^{2}$ –មីនា២០១៧ | ពាន់ម$^{2}$ –មេសា២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ១៣១៧,៣ | ៦៨៧,៦ | ១៣៨៥,៣ |
| ▪ ឧស្សាហកម្ម | ៣៣,៨ | ៨២,៩ | ៥៣៨,៣ |
| ▪ពាណិជ្ជកម្ម | ២១៤១,២ | ៦៣,៣ | ២៦៤៥,៨ |
| ▪ ទេសចរណ៍ | ៣៨,៤ | ៩៤,៦ | ២១,៧ |
| ▪ផ្សេងៗ | ០,៧ | ០,១ | ២,៨ |
| អនុញ្ញាតសរុប | ៣៥៣២ | ៩៣០,៦ | ៤៥៩៤ |

✓ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះ គឺពាណិជ្ជកម្ម៦០,៦% និងលំនៅដ្ឋាន៣៧,៣% នៃផ្ទៃក្រឡាសរុប។

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–មេសា ២០១៧ | នាក់–មីនា ២០១៧ | នាក់–មេសា ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៣១០ | ១១០៨ | ៤៦៣ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១១៩៣៣ | ១២៤៨៧ | ១២១៩៦ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៨៧៣៧ | ៩៩៦៦ | ៨៦៤៣ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣១៩៦ | ២៥២១ | ៣៥៥៣ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មេសា២០១៧ | មីនា២០១៧ | មេសា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៨៧ | ៩១ | ៧៩០,៧ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ៥៥ | ១៧,៧ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៨៧<br>(៥៨) | ៣៦<br>(៨) | ៥៤២,៣<br>(១) |
| វិស័យទេសចរណ៍ | ០ | ០ | ១៩,៨ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ២១១ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១០ | ១៣ | ១៩ |
| បង្កើតការងារ (ពាន់នាក់) | ១៤ | ១៣ | ១៤,៦ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន ៩៧៤,២ពាន់តោនកើនឡើង៦%ធៀបនឹងខែមុន និងកើនឡើង១៦%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៥.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-៣% | (+១៣%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+៣៦% | (-៨២%) |
| ▪ កំពង់ផែកំពង់សោម:+៧% | (+២៣%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៣៣% | (+៣១%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៤,៨ | -២៦% | +៥% |
| ក្នុងនោះទទួល | ២ | -១២% | -៣% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩១,៥ | -២៩% | -៥% |
| ក្នុងនោះទទួល | ៤៦,៤ | -១៩% | -៣% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២២៤១,៤ | -១៧% | -១៥% |
| ក្នុងនោះហៅចូល | ៦៧៨,៣ | -១២% | -១៦% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៨៥៨៥ | +១០% | -១៦% |
| ក្នុងនោះហៅចូល | ៨៥២៧,៩ | +១០% | -១៦% |

## ➢ ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៧,៩ | -២៨% | ៣៣% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៥,៩ | -៤% | ៤៤% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥៧៨,៤ | -១០% | ២៩% |

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៧៦,៩ | ៤៣,៣% | ៣២% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤១២,៩ | -១៤% | ១២% |
| ✓ តាមផ្លូវអាកាស | ២៤៣,៨ | -១៦% | ៣៣% |
| ✓ តាមផ្លូវគោក និងទឹក | ១៦៩,១ | -៩% | -៨% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមេសា ឆ្នាំ២០១៧ មានចំនួន ៤៤៣៩ប៊ីលានរៀល (ស្មើនឹង ១១០៩,៧លានដុល្លារ ស.រ.អា.)ថយចុះ៦,៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៦,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១,៣% | -២,៣% | រថយន្តសរុប (ប៊ី.ល.រ) | -៧,៣% | +២៦,៧% |
| ប្រេងម៉ាស៊ូត | +២៥,៩% | -៩,២% | រថយន្តសរុប (គ្រឿង) | -៩,១% | +៤,១% |
| ឧស្ម័ន | +៤១,១% | +៤៣,៧% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៣,៩% | +១៦,៧% |
| អគ្គិសនីនាំចូល | -៣៩% | -៥៤% | ម៉ូតូ (គ្រឿង) | -១៦,៤% | -៣៤,៤% |
| ដែកសំណង់ | -៤៩,៨% | -១៩,៧% | អង្ករ | +៥៨៦,៥% | -៧៣,១% |
| ស៊ីម៉ង់ត៍ | -១៥,៩% | -១៤% | ផ្លែឈើនិងបន្លែ | +៧,២% | -២២,៤% |
| គ្រឿងអេឡិចត្រូនិក | +០,០% | | ជីនិងថ្នាំកសិកម្ម | +៣៧,៤% | +៨១,២% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៤,៧% | +៥,៤% |

➡ **ការនាំចេញ** ខែមេសា ឆ្នាំ២០១៧ មានចំនួន**៣១៩៥,៥**ប៊ីលានរៀល ស្មើនឹង ៧៩១,៤លានដុល្លារ ស.រ.អា. (**៧១,៣**% នៃការនាំចូល)ថយចុះ១៣,៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៤,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +២០,៦% | -៨២,៤% | ផលិតផលនេសាទ | -៥២,១% | +១៧៦,៩% |
| វាយនភណ្ឌនិងស្បែកជើង | -២៥,៧% | -៦,២% | កៅស៊ូ | -៣២,៨% | +២៣,៤% |
| អង្ករ | -៣៤,៥% | -៩,៧% | | | |

## ៦ .បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមេសា ឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | អគ្គិសនីនាំចូលពីប្រទេសជិតខាង | -៣៩% | -៥៤% | ការផ្គត់ផ្គង់ក្នុងស្រុកមានការកើនឡើងជាពិសេស វារីអគ្គិសនី |
| ២ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក | -៤% | -៨៩% | — |
| ៣ | ការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើង | -២៦% | -៦% | — |

## ៧) សេចក្តីសន្និដ្ឋាន

កម្ពុជាមានតម្រូវការលើសាច់ជ្រូកខ្ពស់ និងកើនឡើងជារៀងរាល់ថ្ងៃ ប៉ុន្តែកសិករចិញ្ចឹមជ្រូកក្នុងស្រុកមិនបានទទួលផលចំណេញពីសក្តានុពលទីផ្សារនេះទេ ព្រោះការនាំចូលយ៉ាងច្រើនសន្ធឹកសន្ធាប់ពីប្រទេសជិតខាង វៀតណាមនិងថៃ បានធ្វើឲ្យថ្លៃធ្លាក់ចុះទាប ធ្វើឲ្យបាត់បង់ឱកាសចំណេញសម្រាប់ពួកគាត់។ មានការលើកឡើងថាកសិករលក់បានតែ ៦០០០-៨០០០ រៀលប៉ុណ្ណោះ ក្នុង១គក្រ.សាច់ជ្រូករស់។ ការធ្លាក់ថ្លៃនេះ ជាចម្បងដោយសារប្រទេសចិនហាមការនាំចូលជ្រូកពីវៀតណាម ជាហេតុនាំឲ្យវៀតណាមបង្វែរការនាំចេញជ្រូកទាំងស្រុងមកប្រកួតប្រជែងជាមួយផលិតកម្មក្នុងស្រុក បង្កឲ្យកសិករចិញ្ចឹមជ្រូកក្នុងស្រុកមានការខាតបង់ និងក្ស័យធនមិនអាចបន្តផលិតកម្មទៀតបាន។ ម្យ៉ាងទៀតកង្វះខាតការត្រួតពិនិត្យអំពីគុណភាពនិងសុវត្ថិភាពពីស្ថាប័ណជំនាញខាងអនាម័យបសុសត្វ និងភូតគាមអនាម័យ ក៏ជាបញ្ហាសំខាន់ ដែលនាំឲ្យប៉ះពាល់ដល់សុខភាពអ្នកបរិភោគយ៉ាងធ្ងន់ធ្ងរ។

ដូច្នេះដើម្បីដោះស្រាយបញ្ហាអវិជ្ជមាននេះ អង្គប្រជុំសុំស្នើវិធានការដូចតទៅៈ សុំឲ្យមានការត្រួតពិនិត្យអនាម័យបសុសត្វ និងភូតគាមអនាម័យនៅតាមព្រំដែន ដើម្បីត្រួតពិនិត្យឲ្យបានម៉ត់ចត់នូវផលិតផលកសិកម្មនាំចូលមិនទាន់កែច្នៃ រួមមានជ្រូក ត្រី សាច់ផ្សេងទៀត និងបន្លែផ្លែឈើ ដើម្បីការពារអ្នកផលិតក្នុងស្រុក រួមទាំងការពារសុខភាពរបស់អ្នកប្រើប្រាស់ផងដែរ។ វិធានការនេះក៏នឹងនាំមកនូវលទ្ធផលវិជ្ជមានផងដែរចំពោះផលិតផលកសិកម្មនាំចេញទៅក្រៅប្រទេសដោយសារប្រទេសនាំចូលផលិតផលកសិកម្មទាំងអស់ តម្រូវអោយមានការបញ្ជាក់ វិញ្ញាបនបត្រអនាម័យបសុសត្វ និងភូតគាមអនាម័យពីស្ថាប័នជំនាញ៕

# IV- សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៧

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៥/១៧ ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៧ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៣/០៥/១៧ ម៉ោង១០:០០នាទី | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ច័ន្ទ តុងអ៊ីវ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៣/០៥/១៧ ម៉ោង១១:០០នាទី | ជួបពិភាក្សាការងារជាមួយលោក **ខែត នរិន្ទជា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៣/០៥/១៧ ម៉ោង១៥:៣០នាទី | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **អ៊ូ ឱឃាត** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៤/០៥/១៧ ម៉ោង០៧:៣០នាទី | ចូលរួមអបអរសាទរខួបទី១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ២០១៧ ក្រោមប្រធានបទ "កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែងសម្រាប់គ្រប់ៗគ្នា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្ដីទី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ និងលោកជំទាវ នៅសាលមហោស្រពខេត្តតាកែវ។ |
| ៦ | ០៦/០៥/១៧ ម៉ោង០៨:៣០នាទី | ចូលរួមកិច្ចប្រជុំពិសេសពាក់ព័ន្ធនឹងការរៀបចំយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ អាណត្តិទី៤ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្ដីទី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល និងជាប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៧ | ០៦/០៥/១៧ ម៉ោង១៣:៣០នាទី | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយប្រធាន និងអនុប្រធានក្រុមបក្សឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្នាក់ការបក្សឃុំ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | **០៧/០៥/១៧ ម៉ោង០៩:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយប្រធាន និងអនុប្រធានក្រុមបក្សឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្នាក់ការបក្សឃុំ។ |
| ៩ | **១០/០៥/១៧ ម៉ោង០៩:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយប្រធាន និងអនុប្រធានក្រុមបក្សឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្នាក់ការបក្សឃុំ។ |
| ១០ | **១១/០៥/១៧ ម៉ោង១០:០០នាទី** | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ផៃន សុទិដ្ឋារ៉ោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **១២/០៥/១៧ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីត្រួតពិនិត្យលើការបើកច្រក VIP បណ្តោះអាសន្នសម្រាប់ប្រើប្រាស់ក្នុងកំឡុងពេលសាងសង់ច្រក VIP ថ្មីរបស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **១៨/០៥/១៧ ម៉ោង០៨:០០នាទី** | ចូលរួមកិច្ចប្រជុំតាមដាន និងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅខេត្តតាកែវ។ |
| ១៣ | **២៣/០៥/១៧ ម៉ោង១៥:៣០នាទី** | ជួបពិភាក្សាការងារជាមួយលោកជំទាវ **តាល់ ណៃអ៊ីម** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២៣/០៥/១៧ ម៉ោង១៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងជាមួយ ឯកឧត្តមអគ្គរដ្ឋទូតបារាំង នៅស្ថានទូតបារាំង។ |
| ១៥ | **២៥/០៥/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមេសា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៦ | **២៧/០៥/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សា សាលាបឋមសិក្សាវត្តភ្នាស ផ្លូវលំ ប្រឡាយទឹក ស្ពាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឋិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅឃុំអង្គប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ។ |
| ១៧ | **២៧/០៥/១៧ ម៉ោង១៣:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីផ្សព្វផ្សាយព្រះរាជសង្ឃប្រកាស អនុសំរេចរមហាសន្និបាតមន្ត្រីសង្ឃទូទាំង ប្រទេសលើកទី២៥ សម្រាប់គណៈធម្មយុត្តិកនិកាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ឋិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅវត្តលឹមពូលសត្យារាម សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។ |



រូបភាពក្នុងវគ្គបណ្ដុះបណ្ដាលអំពីវិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់
នៃលិខិតបទដ្ឋានគតិយុត្ត





រូបភាពក្នុងកិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច
សង្គមកិច្ច និងវប្បធម៌កម្ពុជា



# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in